ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំពិសោធន៍វិទ្យាសាស្ត្រ (Lab Protocol) សម្រាប់ការរៀន និងបង្រៀន នៅមធ្យមសិក្សាទុតិយភូមិ

# មុខវិជ្ជា គីមីវិទ្យា

គាំទ្រដោយគម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
សម្រាប់ការអប់រំមធ្យមសិក្សាទុតិយភូមិ STEP UP

កុម្ភៈ ២០២៥

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានការកំណែទម្រង់វិស័យអប់រំ ដោយផ្តោតលើការពង្រឹងគុណភាពអប់រំនៅគ្រប់កម្រិតសិក្សា និងការបង្កើនការចូលរៀនមុខវិជ្ជាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជាពិសេសការលើកកម្ពស់ការអប់រំស្ទែម ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍធនធានមនុស្សសម្រាប់សង្គម និងសេដ្ឋកិច្ចកម្ពុជា នាសតវត្សរ៍ទី២១។

ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងផ្តល់ការគាំទ្រទាំងផ្នែករឹង និងផ្នែកទន់ដល់សាលារៀន ដូចជា ការធ្វើទំនើបកម្មថ្នាក់រៀន បន្ទប់ពិសោធន៍ ការបំពាក់សម្ភារៈ និងឧបករណ៍ពិសោធន៍ ការផ្តល់ឯកសារគាំទ្រដល់ការរៀន និងបង្រៀន ការបំប៉ននិងបង្វឹកគ្រូបង្រៀន និងការលើកកម្ពស់ការសិក្សាបន្ថែមក្រៅម៉ោង។ ទន្ទឹមគ្នានេះ **សៀវភៅណែនាំពិសោធន៍វិទ្យាសាស្ត្រ និងការផលិតវីដេអូពិសោធន៍វិទ្យាសាស្ត្រ**(Lab Protocol) **សម្រាប់ការរៀន និងបង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិ** ត្រូវបានរៀបចំឡើងដើម្បីបន្ស៊ីទៅនឹងតម្រូវការនៃការអនុវត្តជាក់ស្តែងលើការរៀន និងបង្រៀនពិសោធន៍ និងការអប់រំស្ទែម សម្រាប់ជួយលើកកម្ពស់គុណភាពនៃបង្រៀន និងរៀននៅមធ្យមសិក្សាទុតិយភូមិ ដោយមានការចូលរួមពីក្រុមគ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ ក្រុមការងារបច្ចេកទេសនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា គ្រូបង្រៀនសាលារៀនជំនាន់ថ្មីនៃវិទ្យាល័យព្រះស៊ីសុវត្ថិ និងគ្រូបង្រៀនវិទ្យាល័យធនធាន ក្រោមការគាំទ្រថវិកាពីគម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំកម្រិតមធ្យមសិក្សា(STEP-UP)។ សៀវភៅណែនាំនេះ នឹងជួយគាំទ្រដល់ការអនុវត្តការពិសោធវិទ្យាសាស្ត្រលើមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ដែលក្នុងមួយមុខវិជ្ជាមានចំនួន១៨ពិសោធន៍ សម្រាប់ថ្នាក់ទី១០ ទី១១ និងទី១២ អមទៅដោយវីដេអូពិសោធន៍វិទ្យាសាស្ត្រ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះក្រុមការងារបច្ចេកទេស និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែង ធ្វើឱ្យសម្រេចបានជាផ្លែផ្កានូវស្នាដៃដ៏មានសារៈសំខាន់នេះទុកជាប្រយោជន៍ដល់អ្នកសិក្សានៅកម្ពុជា។

ថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

ការរីកចម្រើនយ៉ាងឆាប់រហ័សឥតឈប់ឈរ និងការប្រកួតប្រជែងស្វែងរកឧត្តមភាពនៅលើពិភពលោកក្នុងបរិបទសកលភាវូបនីយកម្ម ទាមទារឱ្យប្រទេសនីមួយៗខិតខំបង្កើនគុណភាពផលិតផល និងសេវាកម្មរបស់ខ្លួនឱ្យបានជាអតិបរមា។ ក្នុងកិច្ចការបង្កើននូវមូលធនមនុស្សរបស់ប្រទេសនីមួយៗ ត្រូវការជំនាញជាចាំបាច់ទាំងជំនាញវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រ។ ដោយឡែកចំពោះវិទ្យាសាស្ត្រពិតកិច្ចការពិសោធបានក្លាយជាកត្តាដ៏ចាំបាច់មួយដើម្បីឱ្យការអប់រំវិស័យនេះមានភាពរឹងមាំ និងរីកចម្រើន។ ជាអកុសលដោយសារសង្គ្រាមប្រល័យពូជសាសន៍ដែលកើតមានឡើងនាសម័យប៉ុលពតបានបង្អាក់នូវសកម្មភាពផលិត និងបច្ចុប្បន្នភាពនៃឯកសារនៃការអប់រំលើវិស័យនេះ។ យុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៧នៃព្រះរាជាណាចក្រកម្ពុជាបានផ្តោតលើមុំ៥ គឺមនុស្ស ផ្លូវ ទឹក អគ្គិសនី និងបច្ចេកវិទ្យា។ ជាតុផ្សំដ៏សំខាន់សម្រាប់បុគ្គលម្នាក់ក្លាយជាពលរដ្ឋពេញលេញមួយរូប គឺចំណេះដឹង និងជំនាញជាពិសេសផ្នែកវិទ្យាសាស្ត្រ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់អាទិភាពទៅលើឯកសារដែលគាំទ្រដល់ការបណ្តុះបណ្តាលពលរដ្ឋពេញលេញ ហើយក៏បានចាត់វិធានការជាច្រើនដើម្បីជម្រុញ និងលើកទឹកចិត្តដល់គ្រប់ស្ថាប័នអប់រំឱ្យចាប់ផ្តើមផលិត និងធ្វើបច្ចុប្បន្នភាពនូវឯកសារទាំងនោះដើម្បីបំពេញតម្រូវការ និងធ្វើឱ្យការអប់រំនៃវិស័យនេះអាចដើរទាន់សម័យកាលអភិវឌ្ឍដែលបាននិងកំពុងរីកចម្រើនដោយមិនឈប់ឈរនៅប្រទេសអភិវឌ្ឍន៍នានា។

ដើម្បីធានាគុណភាពអប់រំនៅកម្រិតមធ្យមសិក្សាប្រកបដោយគុណភាពខ្ពស់ និងសមស្របតាមស្តង់ដាថ្នាក់ជាតិ និងអន្តរជាតិ គ្រូឧទ្ទេសគីមីវិទ្យាមកពីស្ថាប័ននានាក្រោមឱវាទ ក្រសួងអប់រំ យុវជន និងកីឡា បានសហការ និងព្យាយាមសិក្សា និងស្រាវជ្រាវតាមគ្រប់រូបភាពទាំងអស់ ដើម្បីបង្កើតឱ្យបាននូវខ្លឹមសារ សៀវភៅណែនាំពិសោធន៍គីមី សម្រាប់ជាជំនួយ និងគន្លឹះក្នុងការបណ្តុះបណ្តាលសិស្សានុសិស្ស នៅតាមវិទ្យាល័យនានាទូទាំងព្រះរាជាណាចក្រកម្ពុជាប្រកបដោយសមត្ថភាព និងគុណភាពខ្ពស់លើមុខជំនាញគីមីវិទ្យា។

ការប្រើប្រាស់ធនធនមនុស្សឱ្យអស់លទ្ធភាព មានសារៈសំខាន់បំផុត ពីព្រោះវាជាកម្លាំងចលករមិនអាចខ្វះបាន ជាពិសេសគុណភាពរបស់គ្រូបង្រៀនដែលកំពុងពុះពារលើកកម្ពស់គុណភាពអប់រំគ្រប់ភូមិសិក្សា។ ប្រសិទ្ធភាពនៃការបង្រៀន លើជំនាញឯកទេសទាំងទ្រឹស្តី និងការអនុវត្តមានសារៈសំខាន់ណាស់សម្រាប់សិស្សានុសិស្ស ពីព្រោះវាជាមូលដ្ឋានគ្រឹះ និងជាបទពិសោធទៅកាន់ឧត្តមសិក្សា ដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវគោលនយោបាយនៃរាជរដ្ឋាភិបាល ក៏ដូចជាចក្ខុវិស័យរបស់ក្រសួងអប់រំ ដែលបាននឹងកំពុងយកចិត្តទុកដាក់ទៅលើការធ្វើកំណែទម្រង់វិស័យអប់រំឆ្ពោះទៅរកគុណភាព ដើម្បីលើកស្ទួយប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងឆ្នាំ ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នាឆ្នាំ២០៥០ ។

ក្រុមអ្នកនិពន្ធសង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះនឹងជួយជាគន្លឹះដល់ការបង្រៀនពិសោធន៍ដល់លោកគ្រូ អ្នកគ្រូនៅតាមវិទ្យាល័យនានា ហើយយើងខ្ញុំរង់ចាំទទួលនូវការរិះគន់ស្ថាបនា ដើម្បីកែលម្អឯកសារនេះឱ្យកាន់តែ ល្អប្រសើរ។

**សូមអរគុណ**

ថ្ងៃចន្ទ ១៥កើត ខែបុស្ស ឆ្នាំរោង ឆស័ក ពុទ្ធសករាជ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥

**ក្រុមអ្នកនិពន្ធ**

ចងក្រង និងបោះពុម្ពដោយ៖ វិទ្យាស្ថានជាតិអប់រំ ខែមករា ឆ្នាំ២០២៥
**គាំទ្រថវិកាដោយ៖ គម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំមធ្យមសិក្សា (STEP UP)**
© វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៥

## គណៈកម្មការនិពន្ធ

| | | |
|---|---|---|
| ១) លោកបណ្ឌិត | **អ៊ុំ ចាន់ចំណាន** | គ្រូឧទ្ទេសគីមីវិទ្យានៃវិទ្យាស្ថានជាតិអប់រំ |
| ២) លោក | **ប៉ែន សំភា** | គ្រូឧទ្ទេសគីមីវិទ្យានៃវិទ្យាស្ថានជាតិអប់រំ |
| ៣) លោកស្រី | **ម៉ូរ បូលីនដា** | គ្រូឧទ្ទេសគីមីវិទ្យានៃវិទ្យាស្ថានជាតិអប់រំ |
| ៤) លោកស្រី | **លន់ គូនី** | គ្រូឧទ្ទេសគីមីវិទ្យានៃវិទ្យាស្ថានជាតិអប់រំ |
| ៥) លោកស្រីបណ្ឌិត | **ឯក ពេជ្រមុនី** | គ្រូឧត្តមសិក្សាមហាវិទ្យាល័យគីមីឧស្សាហកម្ម វ.ប.ក |
| ៦) លោកស្រីបណ្ឌិត | **ស្រួយ សេងលី** | គ្រូឧត្តមសិក្សាមហាវិទ្យាល័យគីមីឧស្សាហកម្ម វ.ប.ក |
| ៧) លោក | **ហំ ផល្លី** | គ្រូឧត្តមសិក្សា មហាវិទ្យាល័យវារីសាស្ត្រ វ.ប.ក |
| ៨) លោកបណ្ឌិត | **ហោ ស៊ាងហៃ** | គ្រូឧត្តមសិក្សាគីមីវិទ្យា ស.ភ.ម.ភ |
| ៩) លោក | **ម៉ី សុខុឌ្ឍី** | អនុប្រធានដេប៉ា.គីមីវិទ្យា ស.ភ.ម.ភ |
| ១០) លោកស្រី | **ម៉ុន ដានស៊ីផល** | អនុប្រ.ការិ.នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| ១១) លោក | **គង់ សុផាណ្ណារ៉េត** | មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ១២) លោក | **រឿន រាសី** | គ្រូវិទ្យាល័យព្រះស៊ីសុវត្ថិ-សាលារៀនជំនាន់ថ្មី |
| ១៣) លោក | **ញ៉ែម សុធនរៈ** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យទេពប្រណម្យ |
| ១៤) លោក | **សេង យូហាន** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យកំពង់ស្ពឺ |
| ១៥) លោកស្រី | **ឆេង សុខញ្ញាន** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យកំពង់ស្ពឺ |
| ១៦) លោក | **សិត សុណា** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យកំពង់ស្ពឺ |
| ១៧) លោកស្រី | **រស ដានេ** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យ.ចបទព្រះរាជសម្ភារ |
| ១៨) លោកស្រី | **យឹម ថារី** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យជាស៊ីមតាកែវ |
| ១៩) លោក | **សាន សុផាត** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យជាស៊ីមតាកែវ |
| ២០) កញ្ញា | **យឹង អរីយ៍** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ២១) លោកស្រី | **សៅ សុភាព** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ២២) លោក | **ម៉ក់ ប៉ូលីប៉ាត់** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ២៣) លោក | **គី គុណហ៊ុយ** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យព្រះអង្គឌួង |
| ២៤) លោក | **យ៉ាន់ ខុទ្ធី** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យព្រះអង្គឌួង |
| ២៥) លោក | **អ៊ូ សារ៉ាត់** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យព្រះអង្គឌួង |
| ២៦) លោក | **សេង សោធ** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យស្វាយរៀង |
| ២៧) លោក | **ព្រុំ សុចក្តី** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យស្វាយរៀង |
| ២៨) កញ្ញា | **សុខ ធិតា** | គ្រូបង្រៀនគីមីវិទ្យាវិទ្យាល័យស្វាយរៀង |

## គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១) ឯកឧត្តម | **អ៊ុម រម្យណី** | រដ្ឋលេខាធិការក្រសួង អ.យ.ក. |
| ២) ឯកឧត្តមបណ្ឌិត | **ឌី ខាំបូលី** | អនុប្រធានគ្រប់គ្រងគម្រោងSTEP UP |
| ៣) ឯកឧត្តមបណ្ឌិត | **សៀង សុវណ្ណា** | នាយកវិទ្យាស្ថានជាតិអប់រំ |
| ៤) លោក | **ឌី ឫណ្ណា** | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៥) លោកបណ្ឌិត | **នួច វីរ៉ា** | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៦) លោកស្រី | **ម៉ិន សុផានី** | នាយិការងវិទ្យាស្ថានជាតិអប់រំ |
| ៧) លោក | **ថៃ ហេង** | នាយករងវិទ្យាស្ថានជាតិអប់រំ |

## គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១) លោកបណ្ឌិត | **ម៉ិន គឹមចន់** | នាយករងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| ២) លោក | **ម៉ៅ សារឿន** | ព្រឹទ្ធបុរសមហាវិទ្យាល័យគរុកោសល្យ វ.ជ.អ |
| ៣) លោក | **សម្ប គឹមសាន្ត** | នាយករងវិទ្យាល័យព្រះស៊ីសុវត្ថិ-សាលារៀនជំនាន់ថ្មី |
| ៤) លោកស្រីបណ្ឌិត | **ឡឹយ សុគា** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យគរុកោសល្យ វ.ជ.អ |
| ៥) លោក | **រឿន ឫទ្ធី** | អនុប្រធានការិ.នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| ៦) លោកបណ្ឌិត | **អាន វុ៉ប្រាថ** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យគរុកោសល្យ វ.ជ.អ |
| ៧) លោក | **គួយ សុគាន** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យគរុកោសល្យ វ.ជ.អ |
| ៨) លោក | **ចេង ថុន** | អនុប្រធានដេប៉ាតឺម៉ង់អប់រំ វ.ជ.អ |

## គណៈកម្មការរចនា និងវាយអត្ថបទ

| | | |
|---|---|---|
| ១) លោកស្រី | **អ៊ុំ សោភ័ណ** | អនុប្រធានអង្គភាពកិច្ចការទូទៅ វ.ជ.អ |
| ២) លោក | **ម៉ិនលី ម៉ារឌី** | មន្ត្រីដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ |
| ៣) លោក | **ចាន់ រ៉ាដា** | មន្ត្រីការិយាល័យគណនេយ្យ វ.ជ.អ |
| ៤) លោក | **ឃាង ប៉េងលី** | មន្ត្រីការិយាល័យរដ្ឋបាល វ.ជ.អ |
| ៥) លោក | **ម៉ូត ណារិន** | គ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ |
| ៦) កញ្ញា | **កែវ កញ្ញា** | មន្ត្រីស្ម័គ្រចិត្តដេប៉ាតឺម៉ង់អប់រំ វ.ជ.អ |
| ៧) កញ្ញា | **វីរៈ ខេងឡា** | មន្ត្រីស្ម័គ្រចិត្តដេប៉ាតឺម៉ង់អប់រំ វ.ជ.អ |
| ៨) កញ្ញា | **ជា សុជាតា** | មន្ត្រីស្ម័គ្រចិត្តដេប៉ាតឺម៉ង់អប់រំ វ.ជ.អ |

# មាតិកា


បុព្វកថា.......................................................................................................................i

អារម្ភកថា ..................................................................................................................... ii

គណៈកម្មការនិពន្ធ ............................................................................................................iii

សេចក្ដីណែនាំលើការងារពិសោធទូទៅ.................................................................................. ១

១. វត្ថុបំណង ............................................................................................................. ១

២. ទ្រឹស្តីមូលដ្ឋាន ......................................................................................................... ១

៣. ការបង្កើតសំណួរគន្លឹះ................................................................................................ ១

៥. ឧបករណ៍ និងសារធាតុគីមី..........................................................................................២

៦. ដំណើរការពិសោធ.....................................................................................................២

៧. ការណែនាំលើការប្រើសរសេរសន្លឹកកិច្ចការសិស្ស ............................................................៣

៨. បម្រុងប្រយ័ត្នទូទៅក្នុងដំណើរការពិសោធ .........................................................................៣

៩. កិច្ចការ ក្រោយពិសោធ.................................................................................................៣

ថ្នាក់ទី១០...................................................................................................................... ៤

ប្រធានបទទី១៖ ការរលាយនៃសមាសធាតុកូវ៉ាឡង់ និងសមាសធាតុអ៊ីយ៉ុងក្នុងទឹក ................................. ៥

១. សេចក្ដីណែនាំសម្រាប់គ្រូ ............................................................................................ ៥

២. តារាង Check list.................................................................................................... ៥

៣. សន្លឹកកិច្ចការពិសោធន៍ ...............................................................................................៧

ប្រធានបទទី២៖ ទង្វើ និងអត្តសញ្ញាណកម្មឧស្ម័នអាសេទីឡែន...................................................... ១០

១. សេចក្ដីណែនាំសម្រាប់គ្រូ .......................................................................................... ១០

២. តារាង Check list.................................................................................................. ១០

៣. សន្លឹកកិច្ចការពិសោធន៍............................................................................................. ១២

ប្រធានបទទី៣៖ ប្រតិកម្មរវាងលោហៈសូដ្យូម ជាមួយទឹក និងអត្តសញ្ញាណកម្មអង្គធាតុកកើត............ ១៥

១. សេចក្ដីណែនាំសម្រាប់គ្រូ .......................................................................................... ១៥

២. តារាង Check list........................................................................................................ ១៥
៣. សន្លឹកកិច្ចការពិសោធន៍........................................................................................ ១៧
ប្រធានបទទី៤៖ លក្ខណៈអំផូទែនៃលោហៈអាលុយមីញ៉ូម.................................................................. ២០
១. សេចក្ដីណែនាំសម្រាប់គ្រូ ........................................................................................ ២០
២. តារាង Check list........................................................................................................ ២០
៣. សន្លឹកកិច្ចការពិសោធន៍........................................................................................ ២២
ប្រធានបទទី៥៖ ការចម្លងចរន្តអគ្គិសនីរបស់សមាសធាតុកូវ៉ាឡង់ និងអ៊ីយ៉ុង ........................................ ២៥
១. សេចក្ដីណែនាំសម្រាប់គ្រូ ........................................................................................ ២៥
២. តារាង Check list........................................................................................................ ២៥
៣. សន្លឹកកិច្ចការពិសោធន៍........................................................................................ ២៧
ប្រធានបទទី៦៖ ប្រតិកម្មរវាងម្សៅដែក ជាមួយអាស៊ីតក្លរីឌ្រិច និងអត្តសញ្ញាណកម្មឧស្ម័ន ................ ៣០
១. សេចក្ដីណែនាំសម្រាប់គ្រូ ........................................................................................ ៣០
២. តារាង Check list........................................................................................................ ៣០
៣. សន្លឹកកិច្ចការពិសោធន៍........................................................................................ ៣២
ថ្នាក់ទី១១............................................................................................................................ ៣៥
ប្រធានបទទី១៖ ប្រតិកម្មអុកស៊ីដូរេដុកម្មរវាងបន្ទះស័ង្កសី ជាមួយសូលុយស្យុងទង់ដែង(II)ស៊ុលផាត .. ៣៦
១. សេចក្ដីណែនាំសម្រាប់គ្រូ ........................................................................................ ៣៦
២. តារាង Check list........................................................................................................ ៣៦
៣. សន្លឹកកិច្ចការពិសោធន៍........................................................................................ ៣៨
ប្រធានបទទី២៖ ប្រតិកម្មបំបែកសូដ្យូមប៊ីកាបូណាត និងអត្តសញ្ញាណកម្មឧស្ម័នទទួលបាន ................ ៤១
១. សេចក្ដីណែនាំសម្រាប់គ្រូ ........................................................................................ ៤១
២. តារាង Check list........................................................................................................ ៤១
៣. សន្លឹកកិច្ចការពិសោធន៍........................................................................................ ៤៣
ប្រធានបទទី៣៖ ទំនាក់ទំនងបរិមាណក្នុងប្រតិកម្មគីមី.............................................................. ៤៦
១. សេចក្ដីណែនាំសម្រាប់គ្រូ ........................................................................................ ៤៦

២. តារាង Check list..................................................................................... ៤៦
៣. សន្លឹកកិច្ចការពិសោធន៍.................................................................................... ៤៨
ប្រធានបទទី៤៖ ប្រតិកម្មជំនួសលោហៈក្នុងសូលុយស្យុងអាស៊ីត ................................. ៥១
១. សេចក្តីណែនាំសម្រាប់គ្រូ ................................................................................. ៥១
២. តារាង Check list..................................................................................... ៥១
៣. សន្លឹកកិច្ចការពិសោធន៍....................................................................................៥៣
ប្រធានបទទី៥៖ ទង្វើអាម៉ូញ៉ាក់.............................................................................. ៥៦
១. សេចក្តីណែនាំសម្រាប់គ្រូ ................................................................................. ៥៦
២. តារាង Check list..................................................................................... ៥៦
៣. សន្លឹកកិច្ចការពិសោធន៍.................................................................................... ៥៨
ប្រធានបទទី៦៖ កំណត់ចំនួនម៉ូលេគុលទឹកក្នុងសមាសធាតុអ៊ីដ្រាតេ.................................. ៦១
១. សេចក្តីណែនាំសម្រាប់គ្រូ ................................................................................. ៦១
២. តារាង Check list.....................................................................................៦២
៣. សន្លឹកកិច្ចការពិសោធន៍....................................................................................៦៣
ថ្នាក់ទី១២ .......................................................................................................... ៦៦
ប្រធានបទទី១៖ ស្វ័យកាតាលីស..............................................................................៦៧
១. សេចក្តីណែនាំសម្រាប់គ្រូ .................................................................................៦៧
២. តារាង Check list.....................................................................................៦៧
៣. សន្លឹកកិច្ចការពិសោធន៍.................................................................................... ៦៩
ប្រធានបទទី២៖ ឥទ្ធិពលទំហំភាគល្អិតលើល្បឿនប្រតិកម្ម.............................................៧២
១. សេចក្តីណែនាំសម្រាប់គ្រូ .................................................................................៧២
២. តារាង Check list.....................................................................................៧២
៣. សន្លឹកកិច្ចការពិសោធន៍.................................................................................... ៧៤
ប្រធានបទទី៣៖ ឥទ្ធិពលកាតាលីករលើល្បឿនប្រតិកម្ម និងប្រភេទកាតាលីស.......................៧៧
១. សេចក្តីណែនាំសម្រាប់គ្រូ .................................................................................៧៧

២. តារាង Check list............................................................................................................៧៧
៣. សន្លឹកកិច្ចការពិសោធន៍ ...................................................................................................... ៧៩
ប្រធានបទទី៤៖ ទង្វើសាប៊ូ............................................................................................................ ៨៣
១. សេចក្តីណែនាំសម្រាប់គ្រូ .................................................................................................... ៨៣
២. តារាង Check list............................................................................................................ ៨៣
៣. សន្លឹកកិច្ចការពិសោធន៍ ...................................................................................................... ៨៥
ប្រធានបទទី៥៖ ឥទ្ធិពលនៃសីតុណ្ហភាពលើល្បឿនប្រតិកម្ម............................................................. ៨៨
១. សេចក្តីណែនាំសម្រាប់គ្រូ .................................................................................................... ៨៨
២. តារាង Check list............................................................................................................ ៨៨
៣. សន្លឹកកិច្ចការពិសោធន៍ ...................................................................................................... ៩០
ប្រធានបទទី៦៖ ប្រតិកម្មឈានទៅរកសព្វ(បង្កើតកករ) ................................................................... ៩៣
១. សេចក្តីណែនាំសម្រាប់គ្រូ .................................................................................................... ៩៣
២. តារាង Check list............................................................................................................ ៩៣
៣. សន្លឹកកិច្ចការពិសោធន៍ ...................................................................................................... ៩៥
ឯកសារបន្ថែម ....................................................................................................................... ៩៨
ឯកសារយោង ........................................................................................................................ ៩៩

# សេចក្ដីណែនាំលើការងារពិសោធទូទៅ

## ១. វត្ថុបំណង

ការសរសេរវត្ថុបំណងក្នុងពិសោធន៍នីមួយៗ យើងត្រូវផ្ដោតទៅលើចំណុចសំខាន់ៗបីគឺ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ក្នុងប្រធានបទពិសោធមួយ អ្នករៀបចំពិសោធអាចរៀបរាប់នូវវត្ថុបំណងមិនដូចគ្នាទាំងស្រុងនោះទេ ប៉ុន្តែក្នុងសៀវភៅនេះ អ្នកអាចមើលវត្ថុបំណងជាក់ស្ដែងតាមប្រធានបទពិសោធនីមួយៗបាន។

ប្រធានបទពិសោធអាចមានក្នុងមេរៀនចេញពីចម្ងល់ ឬបាតុភូតដែលអ្នកបានសង្កេតឃើញជុំវិញខ្លួនយើង។ វត្ថុបំណងត្រូវតែប្រើកិរិយាសព្ទសកម្ម ដូចជា កំណត់ គណនា វាស់ ទាញរក ពិនិត្យ ។ល។ ដើម្បីងាយស្រួលក្នុងការវាស់វែង វាយតម្លៃ ឬសន្និដ្ឋាន។ ការសរសេរវត្ថុបំណងត្រូវតែគោរពទៅតាម សកម្មភាព (Action) លក្ខខណ្ឌ (Condition) ស្តង់ដា (Standard)។

## ២. ទ្រឹស្ដីមូលដ្ឋាន

ការសរសេរទ្រឹស្ដីមូលដ្ឋាន គឺការរៀបរាប់ខ្លឹមសារខ្លីៗដូចជាគោលការណ៍ ទ្រឹស្ដី រូបមន្ត ឬបញ្ញត្តិដែលជាពត៌មានចាំបាច់ ជាមូលដ្ឋានត្រូវដឹងជាមុន និងដើម្បីភ្ជាប់ខ្លឹមសារទៅនឹងជីវភាពប្រចាំថ្ងៃ ឬបាតុភូតធម្មជាតិ។ ប្រធានបទនីមួយៗខាងក្រោមនេះ មានភ្ជាប់នូវឧទាហរណ៍នៃទ្រឹស្ដីមូលដ្ឋានសម្រាប់ការពិសោធ ។




## ៣. ការបង្កើតសំណួរគន្លឹះ

សំណួរគន្លឹះ គឺជាចម្ងល់ទៅលើខ្លឹមសារមេរៀន ឬកើតឡើងពីការសង្កេតទៅលើបាតុភូតដែលនៅជុំវិញខ្លួនយើង។ យើងអាចយកវត្ថុបំណងនៃប្រធានបទពិសោធន៍ដែលបានសរសេរមកដាក់ជាសំណួរគន្លឹះបាន។ សំណួរអាចមានច្រើនទម្រង់ពីកម្រិតងាយ ទៅលំបាក ដោយផ្អែកលើទ្រឹស្ដី Bloom Taxonomy។ ផ្អែកលើវត្ថុបំណងនៃប្រធានបទពិសោធ យើងអាចផ្ដល់សំណួរឱ្យទៅសិស្ស ឬស្នើឱ្យសិស្សបង្កើតដោយខ្លួនឯង និងបន្ទាប់មក យើងត្រូវជ្រើសរើសយកសំណួរណាដែលទាក់ទងនឹងវត្ថុបំណង ហើយងាយធ្វើពិសោធន៍។

## ៤. ការបង្កើតសម្មតិកម្ម និងលទ្ធផល

ការបង្កើតសម្មតិកម្មជាការព្យាករណ៍ ឬចម្លើយត្រៀមទុកមុន ទៅលើសំណួរគន្លឹះ ឬចំណោទបញ្ហាដែលបានចោទសួរ។ ការឆ្លើយត្រៀមទុកជាមុន គឺស្ថិតក្នុងលក្ខខណ្ឌដែលអាចរកវិធី ឬសម្ភារៈសម្រាប់ធ្វើពិសោធបញ្ជាក់បាន។

លោកគ្រូអ្នកគ្រូអាចប្រើ សម្មតិកម្មដែលផ្ដល់ឱ្យជាឧទាហរណ៍ទៅតាមប្រធានបទពិសោធន៍នីមួយៗខាងក្រោម។ លោកគ្រូអ្នកគ្រូគួរតែអនុញ្ញាតឱ្យសិស្សមានឱកាសចូលរួមក្នុងការបង្កើតសម្មតិកម្ម

ពីព្រោះនេះ គឺជាសមត្ថភាពចាំបាច់សម្រាប់ពួកគាត់ក្លាយជាអ្នកស្រាវជ្រាវដ៏ឈ្លាសវៃម្នាក់នាពេលអនាគត។

- ជាទូទៅ សម្មតិកម្មទាំងនេះអាចមានតួនាទីសំខាន់ក្នុងការតម្រង់ទិសនៃដំណើរការពិសោធ។
- លទ្ធផលនៃពិសោធគួរតែកត់ត្រាជាតារាង ឬក្រាហ្វ ដើម្បីពន្លឿនការចែករំលែកទិន្នន័យ។ ការបង្កើតតារាងលទ្ធផលសម្រាប់កត់ត្រា តែងតែធ្វើឡើង ដោយយោងទៅតាមការតេស្តសម្មតិកម្ម។

## ៥. ឧបករណ៍ និងសារធាតុគីមី

- ប្រសិនបើអាច គួរបង្ហាញរូបភាពឧបករណ៍នីមួយៗ និងរូបភាពពេលដំឡើងរួច (សម្រាប់ដំណើរការស្មុគស្មាញ) ចំណែកសារជាតុគីមី ត្រូវរៀបរាប់ប្រភេទសារជាតុគីមី ទាំងឈ្មោះ រូបមន្ត ព្រមទាំងបញ្ជាក់ឱ្យច្បាស់ពីបរិមាណសមស្របដែលត្រូវប្រើ។

- ប្រសិនបើក្នុងទីពិសោធមានការខ្វះខាត សម្ភារៈពិសោធ លោកគ្រូ អ្នកគ្រូគួរព្យាយាមរកសម្ភារៈងាយៗនៅក្នុងសហគមន៍មកប្រើជំនួសតាមដែលអាចធ្វើបាន។

***មុនចាប់ផ្តើមដំណើរការពិសោធ គ្រូត្រូវរៀបចំសម្ភារៈ និងសារជាតុគីមីឱ្យបានគ្រប់គ្រាន់ និងសាកល្បងធ្វើពិសោធឱ្យបានច្រើនដង ដើម្បីដឹងលទ្ធផលជាមុន និងបង្ការបញ្ហាដែលកើតមានកំឡុងពេលពិសោធន៍។ ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួនតាមបទបញ្ជាផ្ទៃក្នុងនៃទីពិសោធន៍។***

## ៦. ដំណើរការពិសោធ

- ចំពោះដំណើរការពិសោធ យើងត្រូវសរសេរលេខបញ្ជាក់ជំហានឱ្យច្បាស់តាមលំដាប់លំដោយ ដើម្បីកុំឱ្យក្រុមសិស្សអនុវត្តរំលង ឬខុសលំដាប់លំដោយនាំឱ្យខាតពេល។
- ពេលខ្លះក្រុមសិស្សត្រូវធ្វើដំណើរការពិសោធពីរ ឬច្រើនដូចគ្នា ប៉ុន្តែចាប់ផ្តើមពីជំហានផ្សេងគ្នា។ **ឧទាហរណ៍៖** ពិសោធន៍ទី១ មាន៦ជំហាន ហើយពិសោធន៍ទី២ មានដំណើរការដូចពិសោធន៍ទី១ ប៉ុន្តែចាប់ផ្តើមពីជំហានទី៣ ទៅ៦ នៃពិសោធន៍ទី១ (យើងគ្រាន់តែបញ្ជាក់ប្រាប់ថា ពិសោធន៍ទី២ ធ្វើដូចពិសោធន៍ទី១ ដោយចាប់ពីជំហានទី៣ ដល់ទី៦)។
- ដើម្បីជាជំនួយឱ្យសិស្សងាយយល់ គ្រូអាចប្រើរូបភាពដំណើរការពិសោធ ជំនួសការសរសេររៀបរាប់។
- សម្រាប់សកម្មភាពរៀបចំណាដែលប្រើរយៈពេលយូរ យើងត្រូវរៀបចំឱ្យរួចស្រេចជាមុន ដើម្បីកុំឱ្យដំណើរការពិសោធចំណាយពេលច្រើន ឬហួសម៉ោង។
- ការប្រុងប្រយ័ត្ននៅពេលធ្វើពិសោធ ត្រូវបញ្ជាក់ឱ្យច្បាស់ពីវិធីការពារគ្រោះថ្នាក់ ដូចជាត្រូវពាក់វ៉ែនតា ពាក់ស្រោមដៃ ឬត្រូវធ្វើក្នុងទូសម្រូបជាដើម។

## ៧. ការណែនាំលើការប្រើសរសេរសន្លឹកកិច្ចការសិស្ស

ចំណុច ពិភាក្សា និងសន្និដ្ឋាន **គួរត្រូវរៀបចំដោយគ្រូ ដើម្បីឱ្យសិស្សប្រើក្នុងពេលពិសោធ។** ទម្រង់សន្លឹកកិច្ចការខាងលើនេះ លោកគ្រូ អ្នកគ្រូអាចប្រើកម្រិតណាមួយ ក្នុងចំណោម៣កម្រិត អាស្រ័យទៅនឹងវិធីសាស្ត្របង្រៀនតាមបែបរិះរក (IBL) របស់លោកគ្រូ អ្នកគ្រូ។

- ចំពោះកម្រិត១ ៖ គ្រូត្រូវផ្តល់ឱ្យសិស្សនូវសំណួរគន្លឹះ និងដំណើរការពិសោធ ប៉ុន្តែសិស្សត្រូវធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯង។
- ចំពោះកម្រិត២ ៖ គ្រូត្រូវផ្តល់ឱ្យសិស្សនូវសំណួរគន្លឹះ ប៉ុន្តែសិស្សត្រូវរៀបចំដំណើរការពិសោធ និងធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯង។
- ចំពោះកម្រិត៣ ៖ សិស្សជាអ្នកលើកឡើងនូវសំណួរគន្លឹះ ត្រូវរៀបចំដំណើរការពិសោធ និងធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯង។
- ប្រសិនបើគ្រប់ជំហានទាំងអស់ត្រូវបានគ្រូជាអ្នកផ្តល់គំនិតណែនាំ ចំណែកសិស្សគ្រាន់តែអនុវត្តតាម នោះទម្រង់ការរៀននិងបង្រៀនតាមបែបរិះរកនេះ ចាត់ទុកថាកម្រិតសូន្យ។

## ៨. ប្រុងប្រយ័ត្នទៅក្នុងដំណើរការពិសោធ

សូមអានបទបញ្ជាផ្ទៃក្នុងនៃទីពិសោធន៍ឱ្យបានច្បាស់លាស់ មុនចាប់ផ្តើមពិសោធ។







## ៩. កិច្ចការ ក្រោយពិសោធ

ជាការពិតណាស់ អ្នកពិសោធទាំងអស់ត្រូវចាប់ផ្តើមបង្កើតទម្លាប់រៀបចំទុកដាក់ទិន្នន័យ វិភាគ និងសម្អាតឧបករណ៍ពិសោធដែលខ្លួនប្រើរៀងៗខ្លួន។ ទិន្នន័យទាក់ទងនឹងការពិសោធនីមួយៗ សុទ្ធតែមានប្រយោជន៍ដែលអាចប្រើប្រាស់ទៅតាមការរៀបរៀង និងទៅតាមតម្រូវការអ្នកពិសោធ។ ចូរចងចាំថា ទិន្នន័យ និងលទ្ធផលនៃការពិសោធនានាដែលទទួលបាន ហើយខុសពីការរំពឹងទុករបស់អ្នកពិសោធ មិនមែនជាការបរាជ័យទេ តែវាអាចជាការរៀនសូត្រ ឬរបកគំហើញថ្មី។ លទ្ធផលទាំងនោះអាចរៀបចំជាកិច្ចតម្រង់ទិសសម្រាប់ការពិសោធបន្ទាប់។ ការធ្វើកិច្ចការនេះនឹងបង្កើតបានជាទម្លាប់ល្អមួយដែលអាចរៀបចំអ្នកពិសោធឱ្យក្លាយជាអ្នកពិសោធដ៏ល្អមួយនាពេលអនាគត។ ដើម្បីសម្រេចបាននូវគុណតម្លៃរបស់ទិន្នន័យនីមួយៗដែលបានមកពីការពិសោធ អ្នកពិសោធគួរតែយកទិន្នន័យទាំងនោះទៅពិភាក្សាជាមួយមិត្តភក្តិរួមពិសោធ ឬគ្រូដឹកនាំដើម្បីទទួលបាននូវការកែតម្រូវចំណុចខ្វះខាតនៃ វិធីសាស្ត្រពិសោធ។

# ពិសោធន៍
# ថ្នាក់ទី១០

# មេរៀនថ្នាក់ទី១០

# ប្រធានបទទី១៖ ការរលាយនៃសមាសធាតុកូវ៉ាឡង់ និងសមាសធាតុអ៊ីយ៉ុងក្នុងទឹក

## ១. សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្មនិងប្រសិទ្ធភាពលោកគ្រូ អ្នកគ្រូត្រូវអានសេចក្តីណែនាំខ្លីៗដូចខាងក្រោម៖

1. អានតារាង Check list ខាងក្រោមឱ្យបានយល់ច្បាស់។
2. រៀបចំ ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា សម្ភារពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។
3. អាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១) ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ឬក្រៅថ្នាក់ធម្មតា និង (២) ជាការសិក្សាបែបគម្រោង។
4. ក្នុងករណី (១) ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom) ។
5. ក្នុងករណី (២) ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញនៅពេលបន្ទាប់ពីក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផល នៃការសិក្សាបែបគម្រោងរបស់ពួកគេ។
6. ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ
   - ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
   - ☐ ឆ្លើយសំណួរផ្ទាល់មាត់
   - ☐ ធ្វើបទបង្ហាញជាក្រុម។
7. ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាពុំគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

## ២. តារាង Check list

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| មុនពិសោធន៍ (☑ Check list) | |
|---|---|
| គ្រូ | សិស្ស |
| ☐ ចំណាងជើងជំពូកទី៣ **សម្ព័ន្ធគីមី និង ទម្រង់អង្គធាតុរឹង** មេរៀនទី២ **ទម្រង់អង្គធាតុរឹង** ទំព័រ 69-72 បានរៀន រួចហើយ។ | ☐ បានអាន និងរៀនទ្រឹស្តី<br>☐ បានអាន និងយល់ពីដំណើរការពិសោធន៍ ដែលគ្រូបានចែកឱ្យ រួចបង្កើតសម្មតិកម្ម រួចបង្កើតសម្មតិកម្ម |

| | |
|---|---|
| □ សារធាតុគីមី៖ ស្ករស ($C_{12}H_{22}O_{11}$) អំបិលសម្ល(NaCl) ប្រេងឆា និងទឹក។<br>□ ឧបករណ៍ពិសោធន៍៖ កែវបេស៊ែចំណុះ 100 mL ឬកែវប្លាស្ទិកថ្លា ចំនួន ៤ ចង្កឹះកែវ ៤ ស្លាបព្រាកាហ្វេ ស៊ីរ៉ាំងចំណុះ 20 mL បានរៀបចំរួចរាល់។<br>□ សន្លឹកកិច្ចការ ពិសោធន៍សម្រាប់សិស្សត្រូវបានចែកឱ្យសិស្សរួចរាល់ដូចមានភ្ជាប់ខាងក្រោម។<br>□ បានបែងចែកក្រុម និងកំណត់តួនាទីសមាជិកម្នាក់ៗ ឱ្យបានច្បាស់លាស់ (សមាជិកអាច ពី៤ទៅ៦នាក់ក្នុងមួយក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។<br>□ ត្រូវពិសោធសាកល្បងឱ្យបានយ៉ាងតិចមួយដង។<br>□ ធ្វើការវាយតម្លៃមុនពិសោធន៍តាមក្រុម។ | □ បានមើលវីដេអូពិសោធន៍ និងឯកសារពាក់ព័ន្ធរួចហើយ<br>□ បំណែងចែកតួនាទីសមាជិកក្រុម<br>□ បំពេញសន្លឹកកិច្ចការមុននឹងពិសោធតាមក្រុម<br>□ ទស្សនាវីដេអូពិសោធន៍ និងអនុវត្តតាមការណែនាំនៃការទស្សនាវីដេអូ |

| ពេលធ្វើពិសោធន៍ (☑ Check list) | |
|---|---|
| គ្រូ | សិស្ស |
| □ រំឭកដំណើរការពិសោធន៍<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុស ឬផ្តល់គន្លឹះដល់សិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ ពិនិត្យសកម្មភាព និងលទ្ធផលពិសោធន៍។ | □ ត្រូវតែប្រើប្រាស់សម្ភារៈសុវត្ថិភាព(អាវពិសោធន៍ វ៉ែនតាសុវត្ថិភាព ...)<br>□ រៀបចំសម្ភារៈ និងជាតុគីមីតាមដំណើរការពិសោធន៍<br>□ ប្រធានក្រុមដឹកនាំពិសោធន៍តាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា<br>□ សម្អាតសម្ភារពិសោធន៍ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ រៀបចំសម្អាតបន្ទប់ពិសោធន៍។ |

| ក្រោយពិសោធន៍ (☑ Check list) | |
|---|---|
| គ្រូ | សិស្ស |

| | |
|---|---|
| □ វាយតម្លៃសន្លឹកកិច្ចការពិសោធន៍ និងដាក់ពិន្ទុ<br>□ ដាក់ពិន្ទុចម្លើយផ្ទាល់មាត់។ | □ បំពេញព័ត៌មានសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការវាយតម្លៃ<br>□ ឆ្លើយសំណួរផ្ទាល់មាត់ ។ |

កិច្ចការដែលត្រូវធ្វើ៖

- បញ្ជីត្រួតពិនិត្យ និងសន្លឹកកិច្ចការពិសោធន៍
- សន្លឹកកិច្ចការវាយតម្លៃ
- រៀបចំសម្ភារពិសោធន៍(ជ្រើសរើសសិស្សស្ម័គ្រចិត្ត)
- វិធីសាស្រ្តក្នុងការវាយតម្លៃ៖ ពិនិត្យសន្លឹកកិច្ចការ និងសំណួរផ្ទាល់មាត់។

QR វីដេអូពិសោធន៍

## ៣. សន្លឹកកិច្ចការពិសោធន៍

### ក. សេចក្តីផ្តើម

សារធាតុកូវ៉ាឡង់មានពីរប្រភេទគឺ សារធាតុកូវ៉ាឡង់ប៉ូលែ និងមិនប៉ូលែ។ សារធាតុកូវ៉ាឡង់ប៉ូលែបង្កឡើងពីអាតូមអលោហៈប្រភេទខុសគ្នា និងមានអាតូមមួយមានចំណូលអេឡិចត្រុងខ្លាំងធៀបទៅនឹងអាតូមផ្សេងទៀតបង្កើតបានជាបន្ទុកវិជ្ជមាន និងអវិជ្ជមាននៅភាគម្ខាងៗក្នុងម៉ូលេគុល ដូចជាទឹក ($H_2O$) អាតូមអុកស៊ីសែន(O) មានបន្ទុកអវិជ្ជមានដោយផ្នែក និងអាតូមអ៊ីដ្រូសែនទាំងពីរមានបន្ទុកវិជ្ជមានដោយផ្នែក។

ខាងក្រោមនេះជាលំនាំពិសោធន៍មួយទាក់ទងនឹងការរលាយចូលគ្នានៃសារធាតុកូវ៉ាឡង់ជាមួយសារធាតុអ៊ីយ៉ុង និងសារធាតុកូវ៉ាឡង់ជាមួយសារធាតុកូវ៉ាឡង់។

### ខ. វត្ថុបំណង

- **វិជ្ជាសម្បទា៖** ពន្យល់ពីការរលាយនៃសារធាតុកូវ៉ាឡង់ និងសារធាតុអ៊ីយ៉ុងនៅក្នុងទឹកបានច្បាស់លាស់។
- **បំណិនសម្បទា៖** ញែកសម្គាល់ការរលាយនៃសារធាតុកូវ៉ាឡង់ និងសារធាតុអ៊ីយ៉ុងតាមរយៈពិសោធន៍។
- **ចរិយាសម្បទា៖** យកចិត្តទុកដាក់ក្នុងការប្រើប្រាស់សារធាតុទាំងឡាយដែលអាចរលាយចូលគ្នាបានត្រឹមត្រូវក្នុងជីវភាពប្រចាំថ្ងៃ។

### គ. ដំណើរការបង្រៀន

**សំណួរគន្លឹះ៖**

តើអំបិលសម្ល ស្ករស និងប្រេងឆា រលាយក្នុងទឹកដែរឬទេ?

## សម្មតិកម្ម

----------------------------------------------------------------------------------------------------------------

----------------------------------------------------------------------------------------------------------------

----------------------------------------------------------------------------------------------------------------

----------------------------------------------------------------------------------------------------------------

## សម្ភារៈ

- **ឧបករណ៍**










**កែវបេសឺ ចំណុះ 100 mL** **ចង្កឹះកែវ** **សឺរ៉ាំង ចំណុះ 20 mL** **ស្លាបព្រាកាហ្វេ**

- **សារធាតុគីមី**










**ទឹកសុទ្ធ** **ប្រេងឆា** **អំបិលសម្ល** **ស្ករស**

## ដំណើរការពិសោធ

1. បិទស្លាកទៅលើកែវទាំង4តាមលំដាប់ 1 2 3 4 ។
2. ចាក់ទឹកសុទ្ធ 50 mL ចូលក្នុងកែវទាំង4 (1 2 3 4) ។
3. ចាក់ទឹកសុទ្ធ 20 mL ចូលក្នុងកែវទី1 រួចយកចង្កឹះកែវកូររយៈពេល 2 នាទី។ សង្កេតមើល និងកត់ត្រាលទ្ធផលដាក់ក្នុងតារាងខាងក្រោម។
4. ធ្វើដូចដំណាក់កាលទី៣ដែរដោយចាក់ប្រេងឆា 20 mL ចូលក្នុងកែវទី2 រួចយកចង្កឹះកែវកូររយៈពេល

2 នាទី។ សង្កេតមើល និងកត់ត្រាលទ្ធផលដាក់ក្នុងតារាងខាងក្រោម។

5. ធ្វើដូចករណីប្រេងឆាដែរ ចំពោះអំបិលសម្ល និងស្ករស ដោយចាក់ក្នុងកែវទី3 និងទី4តាមរៀងគ្នា។

## លទ្ធផលពិសោធន៍

តារាងលទ្ធផល៖

| កែវទី | សារធាតុបន្ថែម | រលាយ | មិនរលាយ |
|---|---|---|---|
| 1 | ទឹក | | |
| 2 | ប្រេងឆា | | |
| 3 | អំបិលសម្ល | | |
| 4 | ស្ករស | | |

## ពិភាក្សា

យោងលទ្ធផលតារាងខាងលើ៖

1. តើទឹកជាសារធាតុកូវ៉ាឡង់ប៉ូលែ ឬកូវ៉ាឡង់មិនប៉ូលែ? ចូរពន្យល់។

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

2. តើអំបិលសម្ល( NaCl )ជាសារធាតុអ៊ីយ៉ុង កូវ៉ាឡង់ប៉ូលែ ឬកូវ៉ាឡង់មិនប៉ូលែ ? ចូរពន្យល់។

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

3. តើស្ករស( $C_{12}H_{22}O_{11}$ ) ជាសារធាតុអ៊ីយ៉ុង កូវ៉ាឡង់ប៉ូលែ ឬកូវ៉ាឡង់មិនប៉ូលែ ? ចូរពន្យល់។

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

4. តើប្រេងឆា ជាសារធាតុអ៊ីយ៉ុង កូវ៉ាឡង់ប៉ូលែ ឬកូវ៉ាឡង់មិនប៉ូលែ ? ចូរពន្យល់។

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

## សន្និដ្ឋាន

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------------

# មេរៀនថ្នាក់ទី១០
# ប្រធានបទទី២៖ ទង្វើ និងអត្តសញ្ញាណកម្មឧស្ម័នអាសេទីឡែន

## ១. សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្មនិងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអាន

សេចក្តីណែនាំខ្លីៗដូចខាងក្រោម៖

1. អានតារាង Check list ខាងក្រោមឱ្យបានយល់ច្បាស់។

2. រៀបចំ ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា សម្ភារពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

3. អាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១) ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ឬក្រៅថ្នាក់ធម្មតា និង (២) ជាការសិក្សាបែបគម្រោង។

4. ក្នុងករណី (១) ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)។

5. ក្នុងករណី (២) ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទីនិងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញនៅពេលបន្ទាប់ពីក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផល នៃការសិក្សាបែបគម្រោងរបស់ពួកគេ។

6. ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម។

7. ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាពុំគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

## ២. តារាង Check list

គ្រូនិងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| មុនពិសោធន៍ (☑ Check list) | |
|---|---|
| គ្រូ | សិស្ស |
| ☐ ចំណាងជើងជំពូកទី៤ **គីមីសរីរាង្គ** មេរៀនទី៣ **អ៊ីដ្រូកាបួមិនទាន់ឆ្អែត** ទំព័រ 94-103 បានរៀនរួចហើយ។ | ☐ បានអាន និងរៀនទ្រឹស្តី |

| | |
|---|---|
| □ សារធាតុគីមី៖ កាល់ស្យូមកាបួ ($CaC_2$) សូលុយស្យុង ឌីអ៊ីយ៉ូត (បេតាឌីន) និងទឹក។<br>□ ឧបករណ៍ពិសោធន៍៖ កែវអ៊ែកឡែន និងធ្នុកទុយោ ស្លាបព្រាកាហ្វេ កែវបេស៊ែ បានរៀបចំរួចរាល់។<br>□ សន្លឹកកិច្ចការពិសោធន៍សម្រាប់សិស្សត្រូវបានចែកឱ្យ សិស្សរួចរាល់ ដូចមានភ្ជាប់ខាងក្រោម។<br>□ បែងចែកក្រុម និងកំណត់តួនាទីសមាជិកម្នាក់ៗឱ្យបានច្បាស់លាស់ (សមាជិកអាចពី ៤ទៅ៦ នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។<br>□ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (លទ្ធផលនិងសន្និដ្ឋាន)។<br>□ ត្រូវពិសោធសាកល្បងឱ្យបានយ៉ាងតិចមួយដង។<br>□ ធ្វើការវាយតម្លៃមុនពិសោធតាមក្រុម។ | □ បានអាន និងយល់ពីដំណើរការពិសោធន៍ ដែលគ្រូបានចែកឱ្យ រួចបង្កើតសម្មតិកម្ម រួចបង្កើតសម្មតិកម្ម<br>□ បានមើលវីដេអូពិសោធន៍ និងឯកសារពាក់ព័ន្ធរួចហើយ<br>□ បំណែងចែកតួនាទីសមាជិកក្រុម<br>□ បំពេញសន្លឹកកិច្ចការមុននឹងពិសោធតាមក្រុម។ |

| ពេលធ្វើពិសោធន៍ (☑ Check list) | |
|---|---|
| គ្រូ | សិស្ស |
| □ វំឭកដំណើរការពិសោធន៍<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសឬផ្តល់គន្លឹះដល់សិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ ពិនិត្យសកម្មភាព និងលទ្ធផលពិសោធន៍ន៍។ | □ រៀបចំសម្ភារៈសុវត្ថិភាព(អាវពិសោធន៍ វ៉ែនតាសុវត្ថិភាព ...)។<br>□ រៀបចំសម្ភារៈ និងជាតុគីមីតាមដំណើរការពិសោធន៍ ។<br>□ ប្រធានក្រុមដឹកនាំពិសោធន៍តាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និង កត់ត្រា<br>□ សម្អាតសម្ភារពិសោធន៍ និង រៀបចំទុកដាក់ឱ្យបានរៀបរយ។<br>□ រៀបចំសម្អាតបន្ទប់ពិសោធន៍។ |

| ក្រោយពិសោធន៍ (☑ Check list) | |
|---|---|
| គ្រូ | សិស្ស |
| □ វាយតម្លៃសន្លឹកកិច្ចការពិសោធន៍ និងដាក់ពិន្ទុ<br>□ ដាក់ពិន្ទុចម្លើយផ្ទាល់មាត់។ | □ បំពេញព័ត៌មានសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការវាយតម្លៃ<br>□ ឆ្លើយសំណួរផ្ទាល់មាត់ ។ |

កិច្ចការដែលត្រូវធ្វើ៖

- ធ្វើបញ្ជីត្រួតពិនិត្យ និងសន្លឹកកិច្ចការពិសោធន៍
- សន្លឹកកិច្ចការវាយតម្លៃ
- គំរូរបាយការពិសោធន៍
- រៀបចំសម្ភារពិសោធន៍(ជ្រើសរើសសិស្សស្ម័គ្រចិត្ត)
- វិធីសាស្រ្តក្នុងការវាយតម្លៃ៖ ពិនិត្យសន្លឹកកិច្ចការ និងសំណួរផ្ទាល់មាត់។ QR វីដេអូពិសោធន៍

## ៣. សន្លឹកកិច្ចការពិសោធន៍

### ក. សេចក្តីផ្តើម

ថ្មស្អុយ មានផ្ទុកកាល់ស្យូមកាបួ ( $CaC_2$ )។ វាជាសារជាតុងាយប្រតិកម្មយ៉ាងខ្លាំងក្លាជាមួយទឹកបង្កើតបានជាឧស្ម័ន អាសេទីឡែន និងកាល់ស្យូមអ៊ីដ្រុកស៊ីត។ ឧស្ម័ននេះងាយឆេះ ដូច្នេះយើងត្រូវមានបម្រុងប្រយ័ត្នខ្ពស់ចំពោះអគ្គីភ័យ ម្យ៉ាងទៀតទឹកកំបោរដែលទទួលបានជាសូលុយស្យុងបាសខ្លាំង។ ឧស្ម័នអាសេទីឡែនជាឧស្ម័នគ្មានពណ៌ គ្មានក្លិន ហើយមានកម្រិតពុលទាប។

### ខ. វត្ថុបំណង

- **វិជ្ជាសម្បទា៖** រៀបរាប់បានច្បាស់លាស់ពីដំណើរការនៃទង្វើអាសេទីឡែន។
- **បំណិនសម្បទា៖** សម្គាល់ឧស្ម័នអាសេទីឡែនដោយប្រើសូលុយស្យុងបេតាឌីន ( Betadine )។
- **ចរិយាសម្បទា៖** បណ្តុះស្មារតីសហការគ្នា និងថេះថែរក្សាបរិស្ថាន។

### គ. ដំណើរការបង្រៀន

**សំណួរគន្លឹះ៖**

តើយើងអាចសម្គាល់ឧស្ម័នអាសេទីឡែនដែលកើតពីប្រតិកម្មរវាងកាល់ស្យូមកាបួនិងទឹកបានដោយវិធីណា?

**សម្មតិកម្ម**

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

**សម្ភារៈ**

- **ឧបករណ៍**



កែវអ៊ែកឡែន




កែវបេស៊ែ



ឆ្នុក



ទុយោ



ស្លាបព្រា

- **សារធាតុគីមី**



កាល់ស្យូមកាប៊ូ ( $CaC_2$ )





ទឹក ( $H_2O$ )





បេតាឌីន ( ស្ូ.$I_2$ )

**ដំណើរការពិសោធ**

1. រៀបចំដំឡើងកែវអ៊ែកឡែន និងធ្នុកដែលភ្ជាប់ជាមួយទុយោ។
2. ចាក់ទឹក( $H_2O$) 50 mL ចូលក្នុងកែវបេស៊ែ រួចបន្តក់បេតាឌីន 2ដំណក់។
3. ដាក់កាល់ស្យូមកាប៊ូ 2-3ដុំតូចៗ ឬម្សៅមួយស្លាបព្រាកាហ្វេ ចូលក្នុងកែវអ៊ែកឡែន រួចបិទធ្នុក ។
4. ចាក់ទឹក( $H_2O$) 50 mL ចូលក្នុងកែវអ៊ែកឡែន ដែលភ្ជាប់ទុយោទៅក្នុងសូលុយស្យុងបេតាឌីន។
5. សង្កេត និងកត់ត្រាប្រតិកម្មដែលកើតឡើង។
6. ឧស្ម័នដែលត្រងបានត្រូវបានធ្វើអត្តសញ្ញាណកម្មដោយសូលុយស្យុងបេតាឌីន។
7. សង្កេតការប្រែប្រួលពណ៌របស់សូលុយស្យុងបេតាឌីន។

**លទ្ធផលពិសោធន៍**

**ទង្វើអាសេទីឡែន**

| ការសង្កេតប្រតិកម្មរវាងកាល់ស្យូមកាប៊ូ និងទឹក | | |
|---|---|---|
| | មុនចាក់ទឹកចូល | ក្រោយចាក់ទឹក |
| កែវអ៊ែកឡែន | ..................... | .......................................... |

**បញ្ជាក់អត្តសញ្ញាណនៃឧស្ម័នអាសេទីឡែន**

| | មុនបង្ហូរឧស្ម័នចូល | ក្រោយបង្ហូរឧស្ម័នចូល |
|---|---|---|
| ពណ៌សូលុយស្យុងបេតាឌីនក្នុងកែវបេស៊ែ | ..................... | ..................................... |

**ពិភាក្សា**

1. ចូរសរសេរសមីការតាងប្រតិកម្មដែលកើតឡើងក្នុងកែវអ៊ែកឡែនក្រោយចាក់ទឹកចូល។

   ................. + ................. $\rightarrow$ ................. + .................
2. ហេតុអ្វីបានជាសូលុយស្យុងក្នុងកែវបេស៊ែបាត់ពណ៌ក្រោយពីឧស្ម័នឆ្លងកាត់? ចូរសរសេរសមីការគីមីតាងប្រតិកម្ម។

   ..........................................................................................................................

   ................. + ................. $\rightarrow$ .................
3. ចូររៀបរាប់ពីបម្រើបម្រាស់ឧស្ម័នអាសេទីឡែនក្នុងជីវភាពប្រចាំថ្ងៃ។

   ..........................................................................................................................

   ..........................................................................................................................

## សន្និដ្ឋាន

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

...............................................................................................................................

# មេរៀនថ្នាក់ទី១០

# ប្រធានបទទី៣៖ ប្រតិកម្មរវាងលោហៈសូដ្យូម ជាមួយទឹក និងអត្តសញ្ញាណកម្មអង្គធាតុកកើត

## ១. សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្មនិងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអាន

សេចក្តីណែនាំខ្លីៗដូចខាងក្រោម៖

1. អានតារាង Check list ខាងក្រោមឱ្យបានយល់ច្បាស់។
2. រៀបចំ ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា សម្ភារពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។
3. អាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១) ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ឬក្រៅថ្នាក់ធម្មតា និង (២) ជាការសិក្សាបែបគម្រោង។
4. ក្នុងករណី (១) ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)។
